សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ ក្រោមប្រធានបទ សម្បត្តិឧបាសក៥យ៉ាង ។

www.hoksavann.org

ថ្ងៃទី២២ កក្កដា ២០១១



ពាក្យថា «ឧបាសក» ប្រែថា អ្នកចូលទៅជិតព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ បើស្ត្រីហៅថា «ឧបាសិកា» ។ ការដល់នូវត្រៃសរណគមន៍ប្រកបដោយលក្ខណៈបីយ៉ាង គឺសទ្ធា បញ្ញា និងជីវិតបរិច្ចាគ គឺជឿការត្រាស់ដឹងរបស់ព្រះពុទ្ធ ជឿព្រះធម៌ជាមាគ៌ាចេញចាកទុក្ខ ជឿព្រះសង្ឃជាអ្នកប្រតិបត្តិល្អតាមធម៌វិន័យពិតមែន ហើយហ៊ានលះបង់ជីវិត ពុំលះបង់ព្រះរតនត្រ័យឡើយ ។ ដើម្បីឲ្យទៅជាឧបាសក ឧបាសិកាពេញលក្ខណៈ ត្រូវលះបង់វិបត្តិ៥យ៉ាង ហើយត្រូវប្រកបដោយសម្បត្តិ៥យ៉ាង ។ សម្បត្តិឧបាសក គឺជាធម្មជាតិ ញុំាងសទ្ធានិងសីលនៃឧបាសកឲ្យពេញបរិបូណ៌និងបរិសុទ្ធប្រពៃ ឈ្មោះថាសម្បត្តិមាន៥យ៉ាង ។

១- សទ្ធោ ហោតិ ឧបាសកមានជំនឿជាក់ច្បាស់និងរឹងមាំក្នុងគុណព្រះរតនត្រ័យ ។ បានសេចក្តីមកទៀតថា ជំនឿគុណព្រះរតនត្រ័យ គឺជំនឿលើកម្មផល ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ។ ជំនឿនេះជាអាទិភាពទីមួយក្នុងដំណើរជីវិតរបស់មនុស្សសត្វ គឺបើមានជំនឿត្រូវ នឹងដឹកនាំជីវិតទៅរកផ្លូវត្រូវ ។ បានសេចក្តីថា មុននឹងប្រតិបត្តិតាមព្រះធម៌ ពុទ្ធសាសនិកជនតែងតែមានជំនឿលើព្រះពុទ្ធជាមុន ។

២- សីលវា ហោតិ ឧបាសកមានសីល មានសេចក្តីថា បន្ទាប់ពីមានជំនឿលើព្រះពុទ្ធហើយ ទើបអនុវត្តតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គ មានការសមាទានសីលជាដើម ។ សីលការវៀរចាកមិនធ្វើអំពើអាក្រក់ដោយកាយវាចា ជាគុណធម៌សំខាន់ចាំបាច់របស់មនុស្សសត្វ ។ បើមនុស្សពុំមានគុណធម៌ គឺសីលការរស់នៅរបស់ពួកគេពុំមានតម្លៃអ្វីឡើយ ថែមទាំងបង្កើតសេចក្តីទុក្ខឲ្យដល់សង្គមមនុស្សផង ។ មនុស្សដែលមានអារ្យធម៌ខ្ពស់ គឺមនុស្សមានគុណធម៌គឺសីល ដោយហោចមានសីល៥ មានការវៀរចាកមិនសម្លាប់ មិនលួចប្លន់ មិនប្រព្រឹត្តកន្លងប្រពៃណីកូនប្រពន្ធប្តីអ្នកដទៃ មិនកុហកឆបោក និងមិនផឹកទឹកស្រវឹងនិងគ្រឿងញៀនគ្រប់ប្រភេទ ដែលនាំឲ្យបៀតបៀនអ្នកដទៃ ។ ការមានសីលធម៌នេះ ពុំមែនសំរាប់តែឧបាសកអ្នកកាន់ព្រះពុទ្ធសាសនាឡើយ តែសំរាប់មនុស្សជាតិទូទៅ ព្រោះការមានសីលធម៌នេះ គឺជាការគោរពសិទ្ធិមនុស្ស ។

៣- ន កោតុហលមង្គលិកោ ហោតិ ឧបាសកមិនជឿមង្គលភ្ញាក់ផ្អើលថាឲ្យសុខចំរើន ។ បានសេចក្តីថា មិនមានជំនឿខុសទៅលើហេតុការណ៍ណាមួយ ដែលកើតឡើងតាមច្បាប់ធម្មជាតិ ដូចជារន្ទះបាញ់ ញ័រផែនដី ភ្លើងភ្លំផ្ទុះជាដើម ដែលពីដើមយល់ថាមានវត្ថុស័ក្តិសិទ្ធិបណ្តាលឲ្យកើតឡើង ។ ជំនឿនេះបានចុះខ្សោយ បន្ទាប់ពីវិទ្យាសាស្ត្របានបង្ហាញហេតុផល ។ ជំនឿខុសមួយផ្សេងទៀត គឺកើតពីមនុស្សបង្កើតឡើង ដោយការបោកប្រាស់ដើម្បីលាភសក្ការៈ ដូចជាយកព្រះពុទ្ធរូបតូចៗទៅលួចកប់ ហើយទៅកាយយកមកថាព្រះផុស តាំងខ្លួនជាសម្តេចជួន-ណាតដឹងជាតិ តាំងខ្លួនជាព្រះសិអារ្យមេត្រីយ៍ រហូតតាំងខ្លួនជាព្រះពុទ្ធអង្គ ។ ជំនឿខុសនាំឲ្យប្រព្រឹត្តខុស និងនាំឲ្យកើតសេចក្តីអន្តរាយច្រើនយ៉ាងណាស់ ដែលមនុស្សទូទៅជាពិសេសឧបាសកឧបាសិកាត្រូវចេះលះបង់នូវជំនឿខុសបែបនេះ ។ ត្រង់នេះព្រះសម្ពុទ្ធបានសំដែងក្នុងកាលាមសូត្រប្រកាសប្រាប់មនុស្សសត្វ កុំឲ្យជឿពាក្យនិយាយតៗគ្នា កុំឲ្យជឿអាការៈខាងក្រៅ កុំឲ្យជឿត្រឹមតែពាក្យសំដីជាវោហាសាស្ត្រជាដើម ។ មុននឹងជឿថាជាយ៉ាងណា ត្រូវពិចារណានិងពិសោធន៍ឲ្យបានល្អិតល្អន់ជាមុនសិន ។ ពាក្យខ្មែរក៏មាននិយាយថា កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្តមណ៍ កុំទុកចិត្តអភិប្រាយ ។ ពាក្យអភិប្រាយខាងចុងនេះ គឺកុំទុកចិត្តអ្នកនិយាយប្រាជ្ញព្រោកខាងក្រៅថាជាការពិតភ្លាម ត្រូវពិចារណាឲ្យដឹងហេតុផលច្បាស់លាស់ ។

៤- កម្មំ បច្ចេតិ នោ មង្គលំ ឧបាសកប្រកាន់ជឿថា កម្មជាកុសលនិងអកុសលតែងតែឲ្យផល មិនប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើមឲ្យផលឡើយ ។ បានសេចក្តីថា ឧបាសកជឿតែកម្មផលល្អអាក្រក់របស់ខ្លួន មិនជឿឫក្សពារវេលា គឺមិនជឿថ្ងៃខែឆ្នាំថាឲ្យផលល្អអាក្រក់ដល់ខ្លួនឡើយ ។ មិនជឿថ្ងៃលិចថ្ងៃអណ្តែត ថ្ងៃនេះល្អថ្ងៃនោះអាក្រក់ឡើយ ។ គាថាមួយពោលថា ពេលណាមនុស្សសត្វទាំងឡាយប្រព្រឹត្តល្អដោយកាយវាចាចិត្ត ពេលនោះឈ្មោះថាជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាខណៈល្អ ជាយាមល្អ ។ ពាក្យនេះជាការពិតណាស់ ឧទាហរណ៍ ម៉ោងនេះឧបាសកម្នាក់ទៅសមាទានសីលតែងសុខកាយសប្បាយចិត្ត ដោយគ្មានទោសសត្រូវនឹងអ្នកដទៃឡើយ ម៉ោងដដែលនោះមនុស្សម្នាក់ទៅលួចប្លន់អ្នកដទៃ ត្រូវប៉ូលិសចាប់ចងឲ្យតុលាការកាត់ទោស ។ ដូច្នេះសុខទុក្ខនោះដោយអំពើរបស់ខ្លួន ពុំមែនដោយពេលវេលានោះឡើយ ។

៥- ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅព្រះពុទ្ធសាសនា ហើយគោរពបូជាឡើយ ។ ទក្ខិណេយ្យបុគ្គលដែលមានចិត្តបរិសុទ្ធដូចជាព្រះអរហន្តមានតែក្នុងព្រះពុទ្ធសាសនា ឯសាសនាដទៃពុំមានឡើយ ព្រោះមិនប្រតិបត្តិតាមអដ្ឋង្គិកមគ្គ ដែលជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

ជនដែលប្រតិបត្តិតាមធម៌ទាំង៥ប្រការនេះ ចាត់ជាឧបាសកឧបាសិកា មានគុណធម៌ពេញលក្ខណៈ អាចឲ្យសង្គមមានការចំរើនលូតលាស់ខាងសីលធម៌ផង និងខាងសាមគ្គីភាពផង ។៚

* *
*